# ពុទ្ធិកសមាគមខ្មែរ, ឥង្ក.

The Cambodian Buddhist Society, Inc.

13800 New Hampshire Avenue, Silver Spring, MD 20904

Tel: (301) 622-6544


## បុណ្យទេសនាមហាជាតក៍

☸ 🕯🕯📖🕯🕯 ☸

បុណ្យទេសនាមហាជាតក៍ គឺជាបុណ្យរំលឹកដល់ព្រឹត្តិការណ៍ដ៏អស្ចារ្យមួយរបស់ព្រះសម្មាសម្ពុទ្ធ កាលទ្រង់សម្តែងបាដិហារ្យបណ្តាលឲ្យភ្លៀងធ្លាក់ជាអស្ចារ្យហៅថាភ្លៀងបោក្ខរព័ស្សក្នុងទីប្រជុំនៃញាតិវង្សានុវង្ស ក្នុងកាលដែលព្រះអង្គយាងទៅកាន់ក្រុងកបិលពស្តុ ដើម្បីប្រោសព្រះញាតិរបស់ព្រះអង្គ ។

បុណ្យទេសនាមហាជាតក៍នេះ ដូនតាខ្មែរយើងតែងតែប្រារព្ធធ្វើឡើងជាប់ជាហូរហែតាំងពីព្រេងនាយរហូតមក ។ ការស្តាប់និងការសម្តែងមហាជាតក៍នេះ មានប្រយោជន៍សំខាន់ណាស់ដល់លោកអ្នកទេសន៍ខ្លួនឯងផង ដល់លោកអ្នកស្តាប់ផង ព្រោះធ្វើឲ្យចេះដឹង ឲ្យយល់អំពីការកសាងបារមី ដើម្បីឲ្យបានត្រាស់ជាព្រះពុទ្ធមួយអង្គនោះ តើត្រូវធ្វើដូចម្តេចខ្លះ ។

ដើម្បីរក្សាទុកនូវទំនៀមទំលាប់ដ៏ថ្លៃថ្នូររបស់ដូនតាយើង ពុទ្ធិកសមាគមខ្មែរ, ឥង្ក. បានសម្រេចរៀបចំឲ្យមានបុណ្យទេសនាមហាជាតក៍នេះ តាមកម្មវិធី និងកាលបរិច្ឆេទដូចតទៅ ៖

## កម្មវិធី និង កាលបរិច្ឆេទ

នៅក្នុងទីវត្តពុទ្ធិការាម លេខ ១៣៨០០ មហាវិថី ញូវហាំស៊ារ ក្រុងស៊ិលវើស្រ្ពិង រដ្ឋម៉េរីឡែន ២០៩០៤

- <u>ថ្ងៃសៅរ៍ ១១ កើត ខែ អស្សុជ ព.ស. ២៥៥៥ ត្រូវនឹងថ្ងៃទី ៨ ខែ តុលា គ.ស. ២០១១</u>

  ម៉ោង ៧:៣០ នាទី ល្ងាច : នមស្ការព្រះរតនត្រ័យ សមាទានសីល ចម្រើនព្រះបរិត្ត ធម្មទេសនា

- <u>ថ្ងៃអាទិត្យ ១២ កើត ខែ អស្សុជ ព.ស. ២៥៥៥ ត្រូវនឹងថ្ងៃទី ៩ ខែ តុលា គ.ស. ២០១១</u>

  ម៉ោង ៧:០០ នាទី ព្រឹក : ប្រគេនយាគូព្រះសង្ឃ

  ម៉ោង ៧:៣០ នាទីព្រឹក : ចាប់ផ្តើមទេសនាមហាជាតក៍

  ម៉ោង ១១:០០ ព្រឹក : ប្រគេនចង្ហាន់ព្រះសង្ឃ

  : បន្តទេសនាមហាជាតក៍រហូតដល់ចប់

សូមអញ្ជើញ លោកយាយ លោកតា លោកមីង លោកមា លោក អ្នកនាង ជាពុទ្ធបរិស័ទទាំងអស់ទៅស្តាប់ទេសនាមហាជាតក៍ ជាមួយយើងខ្ញុំ ដើម្បីអនុមោទនាយកកុសលផលបុណ្យផ្ទាល់ខ្លួនផង និងដើម្បីរក្សាទុកនូវកេរមត៌ករបស់ដូនតាយើង ឲ្យបានគង់វង្សតទៅផង ៕

ក្រុមអភិបាលនៃពុទ្ធិកសមាគមខ្មែរ, ឥង្ក.

តំបន់វ៉ាស៊ិនតុន, ឌី.ស៊ី.

ពុទ្ធិកសមាគមខ្មែរ,ឥង្ក.

The Cambodian Buddhist Society, Inc.

13800 New Hampshire Avenue, Silver Spring, MD 20904

Tel: (301) 622-6544

PROGRAM

for

**DISCOURSE UPON THE VESSANTARA JATAKA**

The ceremony of the discourse upon the Vessantara Jataka is to commemorate a miraculous event in the Buddha's life when He used His Supernatural Power to make lotus-leaf-rain in the assembly of His relatives upon His return to His native town of Kapilavathu immediately after His Enlightenment. It is traditionally celebrated to acknowledge that preaching and listening to the Vessantara Jataka help both preachers and listeners understand the life of the Buddha while he was born Vessantara.

## SCHEDULE

At Vatt Buddhikarama, 13800 New Hampshire Avenue,
Silver Spring, MD 20904

Saturday, October 8, 2011

- 7:30 P.M. : Paying respect to the Triple Gem; Taking the Five Precepts; Chanting the Paritta; Giving the Dhammadesana

Sunday, October 9, 2011

- 7:00 A.M. : Breakfast for the Buddhist monks
- 7:30 A.M. : The Discourse upon the Vessantara Jataka begins
- 11:00 A.M. : Lunch for the Buddhist monks and the discourse upon the Vessantara Jataka will continue without interruption until conclusion.

You, your family and friends are cordially invited to participate in the ceremony of the Discourse upon Vessantara Jataka with us.

The Board of Directors
of the Cambodian Buddhist Society, Inc.
of Greater Washington, D.C.